# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-សាលក្រមព្រហ្មទណ្ឌ

លេខ: ២៦៥ក្រ៧ ផ

ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២

-សំណុំរឿងព្រហ្មទណ្ឌលេខ៤៥៨៩

ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១

-ស៊ើបសួរលេខ:៣៤៨៦

ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២១

-ជំនុំជម្រះលេខ:១៩៥

ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២២

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២ ដែលមានសមាសភាពដូចតទៅ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

- លោកស្រី [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- លោក [redacted] ចៅក្រមប្រឹក្សា
- លោក [redacted] ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

- លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

- លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៤៥៨៩ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ ដែលមានជនជាប់ចោទឈ្មោះ [redacted] ប៊ុនរ៉ៃ ភេទប្រុស កើតថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩៨ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើតភូមិ [redacted] ខេត្តបាត់ដំបង ទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅផ្ទះជួល ភូមិត្រពាំងថ្លឹង១ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] ពុនឈឿន (រ) ម្តាយឈ្មោះ [redacted] មុំ (រ) ជានីតិជន ទោសពីមុនគ្មាន កម្រិតវប្បធម៌ថ្នាក់ទៅ៩។ (បច្ចុប្បន្នកំពុងឃុំខ្លួននៅពន្ធនាគាររាជធានីភ្នំពេញ "PJ" តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ៧៦៧៣ "អ" ដ.ឃ.ដ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២១)។

ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ: លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះជួលគ្មានលេខ ផ្លូវលេខ៤០៤ ក្រុម២ ភូមិថ្មគោល៣ សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ០២និង៥៣នាទីរំលងអាធ្រាត្រ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុនរ៉ៃ។

-ដើមបណ្តឹងរដ្ឋប្បវេណីលេខឈ្មោះ [redacted] ដារ៉ែណត ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ ទីលំនៅផ្ទះជួល ភូមិថ្មគោល៣ សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង១០ និង៣០នាទី ជនរងគ្រោះឈ្មោះ [redacted] ដាណែត ភេទប្រុស អាយុ ២០ឆ្នាំ បានទុកម៉ូតូ ០១គ្រឿង ម៉ាក SUZUKI NEX ពណ៌ស-ទឹកក្រូច ពាក់ស្លាកលេខកំពង់ធំ ១P-១៤៨៨ នៅចំណុចផ្ទះជួល ផ្លូវលេខ៤០៤ ក្រុម០២ ភូមិថ្មគោល៣ សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដោយបានចាក់សោក និងសោច្រវ៉ាក់ជាប់នឹងម៉ូតូ ព្រមទាំងបិទសោទ្វាររបងផ្ទះជួលត្រឹមត្រូវហើយ ជនរងគ្រោះក៏បានឡើងទៅសម្រាកនៅក្នុងបន្ទប់បាត់ ។ លុះដល់ម៉ោង ០២និង៥៣នាទីរំលងអាធ្រាត្រ ថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០២១ ជនរងគ្រោះបានឮសម្លេងមានគេបើកទ្វាររបងខាងមុខផ្ទះជួល ទើបជនរងគ្រោះបានចេញពីក្នុងបន្ទប់ជួលស្រាប់តែឃើញទ្វាររបងចំហហើយបាត់ម៉ូតូទើបជនរងគ្រោះបានឆែកកាមេរ៉ាសុវត្ថិភាពក៏ឃើញសកម្មភាពជនត្រូវចោទចំនួន០៣នាក់បានធ្វើសកម្មភាពកាច់សោទ្វាររបងចេញ-ចូលខាងមុខផ្ទះជួល ហើយចូលធ្វើសកម្មភាពកាច់សោករលួចម៉ូតូរបស់ជនរងគ្រោះទៅបាត់។ ក្រោយមកទើបជនរងគ្រោះបានមកដាក់បណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលចោមចៅទី២ ដើម្បីជួយអន្តរាគមន៍តែម្តង ។ លុះដល់ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង១៦ និង៣០ នាទី ជនរងគ្រោះឈ្មោះ [redacted] ដាណែត ក៏បានឃើញជនជាប់ចោទឈ្មោះ [redacted] ប៊ុនរ៉ៃ ភេទប្រុស កើតឆ្នាំ១៩៩៨ កំពុងតែដើរម្នាក់ឯងនៅតាមផ្លូវបេតុង ភូមិជ្រៃកោង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ នាំយកមកប្រគល់ជូនសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលចោមចៅ២ ដើម្បីធ្វើការសាកសួរ។ ក្រោយពីធ្វើការសាកសួរទទួលបានលទ្ធផលថាជនត្រូវចោទឈ្មោះ [redacted] ប៊ុនរ៉ៃ ពិតជាបានធ្វើសកម្មភាពលួចម៉ូតូរបស់ជនរងគ្រោះពិតប្រាកដមែន ដោយមានបក្ខពួកចំនួន០២នាក់ទៀត គឺឈ្មោះ រ័ត្ន ភេទប្រុស អាយុប្រហែល២៥ឆ្នាំនិងឈ្មោះ រ៉េត ភេទប្រុស អាយុប្រហែល៣៧ឆ្នាំ ។ ក្រោយពីធ្វើការសាកសួរសមត្ថកិច្ចបានឃាត់ខ្លួនជនត្រូវចោទរួចកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

-បានឃើញរបាយការណ៍សំយោគលេខ:២១៦/២០២១ រ.ប.ក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១ របស់អធិការនគរបាលខណ្ឌពោធិ៍សែនជ័យ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ០០៧ អ.យ.ទ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ:៨៧ (គ១) ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ប៊ុនរ៉ៃ បានឆ្លើយថា: នៅម៉ោង០២ និង៥៣នាទី យប់រំលងអាធ្រាត្រឈានចូលថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ មុនពេលសមត្ថកិច្ចនគរបាលឃាត់ខ្លួន ([redacted] ប៊ុនរ៉ៃ) ខ្លួនកំពុងសម្រាកនៅក្នុងផ្ទះសំណាក់ផ្កាថ្កុលមាស ក្នុងភូមិចោមចៅ៣ សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ស្រាប់តែបក្ខពួកចំនួន០២នាក់ ១.ឈ្មោះ រ័ត្ន ភេទប្រុស អាយុប្រហែល ២៥ឆ្នាំ (មុខរបរ និងទីលំនៅមិនពិតប្រាកដ) ២.ឈ្មោះ រ៉េត ភេទប្រុសអាយុប្រហែល ៣៧ឆ្នាំ (មុខរបរ និងទីលំនៅមិនពិតប្រាកដ) បានជិះម៉ូតូ ០១គ្រឿងម៉ាក SUZUKI



Scanned with CamScanner

NEX ពណ៌ទឹកប៊ិច ស៊េរីឆ្នាំ២០១៨ មិនចាំស្លាកលេខ មកហៅឱ្យខ្លួនទៅជួយយកម៉ូតូ ០១គ្រឿង ដែលពួកវាលួចកាត់សោរបងផ្ទះជួលចូលលួចកាត់សោកម៉ូតូលួចបានម៉ូតូ ០១គ្រឿង ប៉ុន្តែដើរមិនឆេះ ។ ក្រោយមកខ្លួនក៏បានឡើងជិះម៉ូតូទៅជាមួយបក្ខពួកខាងលើ ទៅដល់ផ្ទះជួលមួយកន្លែង ស្ថិតនៅភូមិថ្នល់គោល៣ សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ ក៏ឃើញម៉ូតូ០១គ្រឿងម៉ាក SUZUKI NEX ពណ៌ស-ទឹកក្រូច ពាក់ស្លាកលេខ កំពង់ធំ ១P-១៤៨៨ ដែលបក្ខពួកខ្លួនខាងលើលួចកាច់សោកបានសម្រេច ប៉ុន្តែដើរមិនឆេះ ទើបខ្លួនជួយរុញម៉ូតូរបស់បក្ខពួក លួចកាច់សោកម៉ូតូបាននោះយកទៅផ្ញើគេ នៅក្នុងផ្ទះសំណាក់ផ្កាថ្កុលមាស រួចហើយបែកផ្លូវគ្នារៀង១ខ្លួន ដោយខ្លួនបានត្រឡប់ទៅដេកនៅផ្ទះជួលវិញ ។ លុះមកដល់ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង០៩ និង០០នាទី បក្ខពួកឈ្មោះ រ័ត្ន ភេទប្រុស និងឈ្មោះ រ៉េត ភេទប្រុស បានជិះម៉ូតូមកដល់ផ្ទះជួលរបស់ខ្លួន ដោយឱ្យលុយខ្លួនចំនួន ១០០ ដុល្លារអាមេរិកហើយប្រាប់ថាជាថ្លៃលក់ម៉ូតូដែលលួចបានពីយប់មិញ រួចក៏បែកផ្លូវគ្នារហូតតែម្តង ។ រហូតមកដល់ថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង១៦ និង៣០នាទី ខ្លួនក៏បានជិះម៉ូតូ PassApp រួចចុះដើរនៅតាមផ្លូវបេតុង ក្នុងភូមិជ្រៃកោង សង្កាត់ចោមចៅទី៣ ក៏ត្រូវឈ្មោះ [redacted] វាសនា ហៅ តូ ជាប្រជាការពារភូមិ និងម្ចាស់ម៉ូតូ បានឃាត់ខ្លួនប្រគល់ជូនសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលចោមចៅទី២ ដើម្បីធ្វើការសាកសួរតែម្តង ។ រយៈកាលកន្លងមកខ្លួនពុំធ្លាប់ជាប់ពន្ធនាគារនោះទេ ចំណែកគ្រឿងញៀនគឺខ្លួនចេះជក់មានរយៈពេល ០៣ឆ្នាំមកហើយរហូតមកដល់បច្ចុប្បន្ននេះ។

-សូមលោកតុលាការមេត្តាជួយបន្ធូរបន្ថយទោស តែខ្លួនជាមនុស្សល្អ។

-តាមអំណានចំលើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ដាណែត នៅសមត្ថកិច្ចថា: នៅថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង ១៦និង៣០នាទី ខ្លួន([redacted] ដាណែត) បានទុកម៉ូតូ ០១គ្រឿងម៉ាក SUZUKI NEX ពណ៌ស-ទឹកក្រូច លេខតួCT44F360646 លេខម៉ាស៊ីន AE52360569 ពាក់ស្លាកលេខកំពង់ធំ ១P-១៤៨៨ នៅចំណុចផ្ទះជួល ផ្លូវលេខ៤០៤ ក្រុមទី០២ ភូមិថ្នល់គោល៣ សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដោយបានចាក់សោក និងសោរច្រវ៉ាក់ចាក់ជាប់នឹងម៉ូតូ ព្រមទាំងបិទចាក់សោទ្វាររបងផ្ទះជួលត្រឹមត្រូវ ហើយខ្លួនក៏ឡើងទៅស្នាក់នៅក្នុងបន្ទប់ជួលរបស់ខ្លួន នៅក្បែរនោះតែម្តង ។ លុះនៅម៉ោង០២ និង៥៣នាទី យប់រំលងអាធ្រាត្រឈានចូលថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ ខ្លួនបានឮសម្លេងមានគេបើកទ្វាររបងខាងមុខផ្ទះជួល ទើបខ្លួនបានចេញពីក្នុងបន្ទប់ជួលទៅមើល ស្រាប់តែឃើញទ្វាររបងចេញ-ចូលខាងមុខផ្ទះជួលចំហរទ្វារ ព្រមទាំងបាត់ម៉ូតូរបស់ខ្លួនមិនដឹងថាអ្នកណាលួចយកទៅបាត់ក្នុងពេលនោះខ្លួនបានទៅឆែកមើលក្នុងកាមេរ៉ាសុវត្ថិភាព ដែលដាក់ថតនៅជុំវិញផ្ទះជួលក៏ឃើញសកម្មភាពជនត្រូវចោទចំនួន០៣នាក់បានធ្វើសកម្មភាពកាច់សោទ្វាររបងចេញ-ចូលខាងមុខផ្ទះជួលហើយចូលធ្វើសកម្មភាពកាច់សាកលួចម៉ូតូរបស់ខ្លួនចេញទៅបាត់ ។ ក្រោយមកទើបខ្លួនបានមកដាក់ពាក្យបណ្តឹងនៅទីស្នាក់ការប៉ុស្តិ៍នគរបាលរដ្ឋបាលចោមចៅទី២ ដើម្បីឱ្យសមត្ថកិច្ចនគរបាលជួយស្រាវជ្រាវតែម្តង។ លុះដល់ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង១៦ និង៣០នាទី ខ្លួនក៏បានឃើញជនត្រូវចោទឈ្មោះ [redacted] ប៊ុនឆៃ ភេទប្រុស (ដែលជនក្រុមជនត្រូវចោទចំនួន០៣នាក់ធ្វើសកម្មភាពភាពកាច់សោរបងចេញ-ចូលផ្ទះជួល និងកាច់សោកម៉ូតូលួចយកម៉ូតូរបស់ខ្លួន) កំពុងតែដើរម្នាក់ឯងតាមផ្លូវបេតុង ក្នុងភូមិជ្រៃកោង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ

ក៏ធ្វើការឃាត់ខ្លួនជនត្រូវចោទឈ្មោះ [redacted] ប៊ុនរ៉ៃ ភេទប្រុស នាំយកមកប្រគល់ជូនសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលចោមចៅទី២ ដើម្បីធ្វើការសាកសួរតែម្តង។

-តាមអំណានចំលើយសាក្សីឈ្មោះ [redacted] វាសនា បានឆ្លើយថា៖ នៅថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង០៨ និង០០នាទីមុនពេលកើតហេតុខ្លួន (ឈ្មោះ [redacted] វាសនា) កំពុងប្រចាំការ នៅទីស្នាក់ការភូមថ្មគោល៣ សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ភ្លាមនោះស្រាប់តែជនរងគ្រោះឈ្មោះ [redacted] ដាណែត ភេទប្រុស បានមករាយការណ៍ប្រាប់ និងបង្ហាញវីដេអូក្នុងទូរស័ព្ទដៃគាត់ឱ្យដឹងថា មានក្រុមជនត្រូវចោទចំនួន ០៣ នាក់ បានធ្វើសកម្មភាពលួចកាត់សោទ្វាររបងចេញ-ចូលផ្ទះជួល និងលួចកាច់សោកម៉ូតូលួចម៉ូតូ ០១គ្រឿងម៉ាក SUZUKI NEX ពណ៌ស-ទឹកក្រូច ពាក់ស្លាកលេខកំពង់ធំ ១P-១៤៨៨ ទៅបាត់នៅចំណុចផ្ទះជួល ក្នុងភូមិថ្មគោល សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ។ នៅពេលមើលរូបវីដេអូក្នុងទូរស័ព្ទដៃរបស់ជនរងគ្រោះ រួចហើយគឺខ្លួនបានចំណាំមុខនិងភិនភាគ ហើយស្គាល់ជនត្រូវចោទម្នាក់ឈ្មោះ [redacted] ប៊ុនរ៉ៃ ភេទប្រុស ច្បាស់ទើបខ្លួនបានស្រាវជ្រាវរកជនត្រូវចោទ។ លុះមកដល់ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង១៦ និង៣០នាទី ខ្លួនកំពុងជិះម៉ូតូល្បាតនៅតាមភូមិ ក៏ប្រទះឃើញជនត្រូវចោទម្នាក់ឈ្មោះ [redacted] ប៊ុនរ៉ៃ ភេទប្រុស ដើរម្នាក់ឯងនៅតាមផ្លូវបេតុង ក្នុងភូមិជ្រៃកោង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ ទើបខ្លួនបានឃាត់ខ្លួនជនត្រូវចោទឈ្មោះ [redacted] ប៊ុនរ៉ៃ ភេទប្រុស ប្រគល់ជូនសមត្ថកិច្ចនគរបាលតែម្តង។

-តាមអំណានរបាយការណ៍សំយោគសរុបលេខ: ២១៦/២០ រ.ប.ក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១ របស់អធិការនគរបាលខណ្ឌពោធិ៍សែនជ័យ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ឆ្លងតាមសវនាការជនជាប់ចោទឈ្មោះ [redacted] ប៊ុនរ៉ៃ បានឆ្លើយសារភាពថាខ្លួនពិតជាបានលួចម៉ូតូរបស់គេមែន គឺមានភាពស៊ីសង្វាក់ទៅនិងចំលើយដើមបណ្តឹង និងសាក្សី និងវត្ថុតាងចាប់យកដែលដកហូតពីជនជាប់ចោទ គឺមានធាតុផ្សំបទល្មើសគ្រប់គ្រាន់។ ដូចនេះក្នុងនាមអយ្យការតំកល់ការចោទប្រកាន់នេះទុកនៅដដែល សូមក្រុមប្រឹក្សាសម្រេចទៅតាមច្បាប់ចុះ។

## សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិអោយជនជាប់ចោទ

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ភារ៉ាត បានធ្វើសេចក្តីសន្និដ្ឋានថា: ឆ្លងតាមសវនាការកូនក្តីខ្លួនបានឆ្លើយសារភាពទាំងអស់ដោយពុំមានការលាក់លៀមនិងបង្កការលំបាកដល់ការស៊ើបសួររបស់តុលាការឡើយ។ ក្នុងពេលជាប់ពន្ធនាគារកូនក្តីខ្លួនបានកែប្រែ និងកែខ្លួនជាមនុស្សល្អ និងដឹងកំហុសដែលខ្លួនបានប្រព្រឹត្ត កូនក្តីខ្លួនរៀនសូត្រតិចតួចងាយ និងអូសទាញពីមិត្តភក្តិ។ ហេតុនេះសូមលោកក្រុមប្រឹក្សាជំនុំជម្រះផ្តល់ឱកាសដល់កូនក្តីខ្លួនបានកែប្រែខ្លួន និងសូមមេត្តាជួយបន្ធូរបន្ថយទោសបានទាបដើម្បីទៅរួមរស់ក្នុងក្រុមគ្រួសារ និងសង្គមវិញ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] ប៊ុនរ៉ៃ បាននិយាយសម្តីចុងក្រោយបង្អស់ថា: សូមលោកតុលាការមេត្តាជួយ



Scanned with CamScanner

បន្ធូរបន្ថយទោសដោយសន្យាកែខ្លួនជាមនុស្សល្អក្នុងសង្គម។

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់អំណានចម្លើយដើមបណ្ដឹង

-ក្រោយពីបានស្ដាប់អំណានចម្លើយសាក្សី

-ក្រោយពីបានស្ដាប់អំណានឯកសារផ្សេងៗ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានស្ដាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ និងពិចារណាលើសំណុំរឿងចប់សព្វគ្រប់រួចហើយ

## សំអាងហេតុ

-តាមដីកាបញ្ជូនសំណុំរឿងសំណុំរឿងទៅជំនុំជម្រះលេខ៨៧ "គ១" ដ.ដ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១ បានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ប៊ុនរ៉ៃ ភេទប្រុស កើតឆ្នាំ១៩៨៨ ទៅជំនុំជម្រះពីបទ: លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះជួលគ្មានលេខ ផ្លូវលេខ៤០៤ ក្រុម២ ភូមិថ្មគោល៣ សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៥ ខែ តុលា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ០២និង៥៣នាទីរំលងអាធ្រាត្រ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-តាមចំលើយជនជាប់ចោទឈ្មោះ [redacted] ប៊ុនរ៉ៃ បានឆ្លើយថា: នៅម៉ោង០២ និង៥៣នាទី យប់រំលងអាធ្រាត្រឈានចូលថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ មុនពេលសមត្ថកិច្ចនគរបាលឃាត់ខ្លួន ([redacted] ប៊ុនរ៉ៃ) ខ្លួនកំពុងសម្រាកនៅក្នុងផ្ទះសំណាក់ផ្កាថ្កុលមាស ក្នុងភូមិចោមចៅ៣ សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ស្រាប់តែបក្ខពួកចំនួន ០២នាក់ ១.ឈ្មោះ រ័ត្ន ភេទប្រុស អាយុប្រហែល ២៥ឆ្នាំ (មុខរបរ និងទីលំនៅមិនពិតប្រាកដ) ២.ឈ្មោះ រ៉េត ភេទប្រុសអាយុប្រហែល៣៧ឆ្នាំ (មុខរបរនិងទីលំនៅមិនពិតប្រាកដ) បានជិះម៉ូតូ០១គ្រឿង ម៉ាក SUZUKI NEX ពណ៌ទឹកប៊ិច ស៊េរីឆ្នាំ២០១៨ មិនចាំស្លាកលេខ មកហៅឱ្យខ្លួនទៅជួយយកម៉ូតូ ០១គ្រឿង ដែលពួកវាលួចកាត់សោរបងផ្ទះជួលចូលលួចកាត់សោកម៉ូតូលួចបានម៉ូតូ ០១គ្រឿង ប៉ុន្តែដើរមិនឆេះ។ ក្រោយមកខ្លួនក៏បានឡើងជិះម៉ូតូទៅជាមួយបក្ខពួកខាងលើ ទៅដល់ផ្ទះជួលមួយកន្លែង ស្ថិតនៅភូមិថ្មគោល៣ សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ ក៏ឃើញម៉ូតូ០១គ្រឿងម៉ាក SUZUKI NEX ពណ៌ស-ទឹកក្រូច ពាក់ស្លាកលេខកំពង់ធំ ១P-១៤៨៨ ដែលបក្ខពួកខ្លួនខាងលើលួចកាច់សោកបានសម្រេច ប៉ុន្តែដើរមិនឆេះទើបខ្លួនជួយរុញសម៉ូតូរបស់បក្ខពួកលួចកាច់សោកម៉ូតូបាននោះយកទៅដាក់ជៀគេនៅក្នុងផ្ទះសំណាក់ផ្កាថ្កុលមាស រួចហើយបែកផ្លូវគ្នារៀងៗខ្លួនដោយខ្លួនបានត្រឡប់ទៅដេកនៅផ្ទះជួលវិញ។ លុះមកដល់ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង០៩និង០០នាទីបក្ខពួកឈ្មោះ រ័ត្ន ភេទប្រុស និងឈ្មោះ រ៉េត ភេទប្រុស បានជិះម៉ូតូមកដល់ផ្ទះជួលរបស់ខ្លួន ដោយឱ្យលុយខ្លួនចំនួន ១០០ ដុល្លារអាមេរិកហើយប្រាប់ថាជាថ្លៃលក់ម៉ូតូដែលលួចបានពីយប់មិញ រួចក៏បែកផ្លូវគ្នារហូតតែម្ដង។ រហូតមកដល់ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង១៦ និង៣០នាទី ខ្លួនក៏បានជិះម៉ូតូ PassApp រួចចុះដើរនៅតាមផ្លូវបេតុង

ក្នុងភូមិជ្រៃកោង សង្កាត់ចោមចៅទី៣ ក៏ត្រូវឈ្មោះ [redacted] វាសនា ហៅ តូ ជាប្រជាការពារភូមិ និងម្ចាស់ម៉ូតូបាន ឃាត់ខ្លួនប្រគល់ជូនសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលចោមចៅទី២ ដើម្បីធ្វើការសាកសួរតែម្តង។ រយៈកាលកន្លង មកខ្លួនពុំធ្លាប់ជាប់ពន្ធនាគារនោះទេ ចំណែកគ្រឿងញៀនគឺខ្លួនចេះជក់មានរយៈពេល ០៣ឆ្នាំមកហើយ រហូតមក ដល់បច្ចុប្បន្ននេះ។

-សូមលោកតុលាការមេត្តាជួយបន្ធូរបន្ថយទោស កែខ្លួនជាមនុស្សល្អ។

-តាមចំលើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ដាណែត បានឆ្លើយថា នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ វេលាម៉ោង ១៦និង៣០នាទី ខ្លួន(ឈាង ដាណែត) បានទុកម៉ូតូ ០១គ្រឿងម៉ាក SUZUKI NEX ពណ៌ស-ទឹកក្រូច លេខតួCT44F360646 លេខម៉ាស៊ីន AE52360569 ពាក់ស្លាកលេខកំពង់ធំ ១P-១៤៨៨ នៅចំណុចផ្ទះជួលផ្លូវ លេខ៤០៤ ក្រុមទី០២ ភូមិថ្មគោល៣ សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដោយបានចាក់ សោក និងសោរច្រវ៉ាក់ចាក់ជាប់នឹងម៉ូតូ ព្រមទាំងបិទចាក់សោទ្វាររបងផ្ទះជួលត្រឹមត្រូវ ហើយខ្លួនក៏ឡើងទៅស្នាក់ នៅក្នុងបន្ទប់ជួលរបស់ខ្លួន នៅក្បែរនោះតែម្តង ។ លុះនៅម៉ោង០២ និង៥៣នាទី យប់រំលងអាធ្រាត្រឈានចូលថ្ងៃ ទី២៥ ខែតុលា ឆ្នាំ២០២១ ខ្លួនបានឮសម្លេងមានគេបើកទ្វាររបងខាងមុខផ្ទះជួល ទើបខ្លួនបានចេញពីក្នុងបន្ទប់ជួល ទៅមើលស្រាប់តែឃើញទ្វាររបងចេញ-ចូលខាងមុខផ្ទះជួលចំហរទ្វារ ព្រមទាំងបាត់ម៉ូតូរបស់ខ្លួនមិនដឹងថាអ្នកណា លួចយកទៅបាត់ក្នុងពេលនោះខ្លួនបានទៅឆែកមើលក្នុងកាមេរ៉ាសុវត្ថិភាព ដែលដាក់ថតនៅជុំវិញផ្ទះជួលក៏ឃើញ សកម្មភាពជនត្រូវចោទចំនួន ០៣នាក់បានធ្វើសកម្មភាពកាច់សោទ្វាររបងចេញ-ចូលខាងមុខផ្ទះជួល ហើយចូលធ្វើ សកម្មភាពកាច់សាកលួចម៉ូតូរបស់ខ្លួនចេញទៅបាត់ ។ ក្រោយមកទើបខ្លួនបានមកដាក់ពាក្យបណ្តឹងនៅទីស្នាក់ការ ប៉ុស្តិ៍នគរបាលរដ្ឋបាលចោមចៅទី២ ដើម្បីឱ្យសមត្ថកិច្ចនគរបាលជួយស្រាវជ្រាវតែម្តង។ លុះដល់ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១១ វេលាម៉ោង១៦ និង៣០នាទី ខ្លួនក៏បានឃើញជនត្រូវចោទឈ្មោះ [redacted] ប៊ុនឆៃ ភេទប្រុស (ដែលជនក្រុម ជនត្រូវចោទចំនួន០៣នាក់ធ្វើសកម្មភាពភាពកាច់សោរបងចេញ-ចូលផ្ទះជួល និងកាច់សោកម៉ូតូលួចយកម៉ូតូរបស់ ខ្លួន) កំពុងតែដើរម្នាក់ឯងតាមផ្លូវបេតុងក្នុងភូមិជ្រៃកោង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ ក៏ធ្វើការឃាត់ ខ្លួនជនត្រូវចោទឈ្មោះ [redacted] ប៊ុនឆៃ ភេទប្រុស នាំយកមកប្រគល់ជូនសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលចោមចៅទី២ ដើម្បីធ្វើការសាកសួរតែម្តង។

-តាមចំលើយសាក្សីឈ្មោះ [redacted] វាសនា បានឆ្លើយថា: នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង០៨ និង០០នាទីមុនពេលកើតហេតុខ្លួន (ឈ្មោះ [redacted] វាសនា) កំពុងប្រចាំការនៅទីស្នាក់ការក្អមថ្មគោល៣ សង្កាត់ចោម ចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ភ្លាមនោះស្រាប់តែជនរងគ្រោះឈ្មោះ [redacted] ដាណែត ភេទប្រុស បានមករាយការណ៍ប្រាប់ និងបង្ហាញវីដេអូក្នុងទូរស័ព្ទដៃគាត់ឱ្យដឹងថា មានក្រុមជនត្រូវចោទចំនួន ០៣នាក់ បាន ធ្វើសកម្មភាពលួចកាត់សោទ្វាររបងចេញ-ចូលផ្ទះជួល និងលួចកាច់សោកម៉ូតូលួចម៉ូតូ ០១គ្រឿងម៉ាក SUZUKI NEX ពណ៌ស-ទឹកក្រូច ពាក់ស្លាកលេខកំពង់ធំ ១P-១៤៨៨ ទៅបាត់នៅចំណុចផ្ទះជួល ក្នុងភូមិថ្មគោល សង្កាត់ ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ។ នៅពេលមើលរូបវីដេអូក្នុងទូរស័ព្ទដៃរបស់ជនរងគ្រោះ រួចហើយគឺខ្លួនបាន ចំណាំមុខនិងភិនភាគ ហើយស្គាល់ជនត្រូវចោទម្នាក់ឈ្មោះ [redacted] ប៊ុនឆៃ ភេទប្រុស ច្បាស់ទើបខ្លួនបានស្រាវ ជ្រាវរក

ជនត្រូវចោទ។ លុះមកដល់ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង១៦ និង៣០នាទី ខ្លួនកំពុងជិះម៉ូតូល្បាតនៅតាមភូមិ ក៏ប្រទះឃើញជនត្រូវចោទម្នាក់ឈ្មោះ [redacted] ប៊ុនរ៉ៃ ភេទប្រុស ដើរម្នាក់ឯងនៅតាមផ្លូវបេតុង ក្នុងភូមិព្រៃកោង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ ទើបខ្លួនបានឃាត់ខ្លួនជនត្រូវចោទឈ្មោះ [redacted] ប៊ុនរ៉ៃ ភេទប្រុស ប្រគល់ជូនសមត្ថកិច្ចនគរបាលតែម្តង។

-តាមអំណានរបាយការណ៍សំយោគសរុបលេខ:២១៦/២០ រ.ប.ក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១ បានសន្និដ្ឋានថា: ឈ្មោះ [redacted] ប៊ុនរ៉ៃ ភេទប្រុស អាយុ ២៣ឆ្នាំ ពិតជាបាន "លួចម៉ូតូជាមួយបក្ខពួក" កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ នៅចំណុចផ្ទះជួល ផ្លូវលេខ ៤០៤ ក្រុមទី ០២ ភូមិថ្មីគោល៣ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ប្រាកដមែន។

-ផ្អែកតាមចំលើយសារភាពរបស់ជនជាប់ចោទ, របាយការណ៍សរុបរបស់ការិយាល័យព្រហ្មទណ្ឌ និងភស្តុតាងនានាគឺមានភាពស៊ីសង្វាក់គ្នា អាចបញ្ជាក់ថា: ជនជាប់ចោទឈ្មោះ [redacted] ប៊ុនរ៉ៃ ភេទប្រុស ពិតជាបានលួចម៉ូតូ ប្រព្រឹត្តនៅចំណុចផ្ទះជួលគ្មានលេខ ផ្លូវ ៤០៤ ក្រុម២ ភូមិថ្មគោល៣ សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ បទល្មើសតម្រូវឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនរ៉ៃ ចេតនាទុច្ចរិតបានធ្វើសកម្មភាពលួចយកម៉ូតូជនរងគ្រោះក្នុងគោលបំណងលួចទ្រព្យសម្បត្តិពិតប្រាកដមែន។ អំពើរបស់ជននេះ គឺជាអំពើលួចមានស្ថានទម្ងន់ទោសដោយសារប្រព្រឹត្តមានគ្នាច្រើនដែលនាំឲ្យខូចប្រយោជន៍របស់ជនរងគ្រោះ។

-ជនជាប់ចោទឈ្មោះ [redacted] ប៊ុនរ៉ៃ ជានីតិជនសមត្ថភាពអាចទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន។

-អំពើរបស់ជនជាប់ចោទបានធ្វើឲ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម។

-មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] ប៊ុនរ៉ៃ ពីបទ: លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះជួលគ្មានលេខ ផ្លូវលេខ៤០៤ ក្រុម២ ភូមិថ្មគោល៣ សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ វេលាម៉ោងប្រហែល០២និង៥៣នាទីរំលងអាធ្រាត្រ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ដាណែត មិនបានចូលខ្លួនតាមការកោះហៅរបស់តុលាការដើម្បីទាមទារសំណងពីជនជាប់ចោទ គប្បីតុលាការមិនពិចារណាលើសំណងឡើយ។

## <u>ហេតុដូច្នេះសម្រេច</u>

១/ ផ្តន្ទាទោសឈ្មោះ [redacted] ប៊ុនរ៉ៃ ភេទប្រុស កើតថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩៨ ដាក់ពន្ធនាគារចំនួន០៤ឆ្នាំ (បួនឆ្នាំ) ពីបទ: លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះជួលគ្មានលេខ ផ្លូវលេខ៤០៤ ក្រុម២ ភូមិថ្មគោល៣ សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០២១ វេលាម៉ោងប្រហែល០២និង៥៣នាទីរំលងអាធ្រាត្របទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ ជា ប៊ុនអ៊ែ និងមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២។

-មានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ប្រធានក្រុមជំនុំជម្រះ** |
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ៤រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]